# ការបែងចែកមត៌ក

## ក.សញ្ញាណនៃសន្តតិកម្ម

សន្តតិកម្ម ចាប់ផ្តើមដោយសារមរណភាពរបស់មតកជន នៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ហើយសន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ ដែលជាទ្រព្យរបស់មតកជន នៅពេលចាប់ផ្តើមសន្តតិកម្ម (គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ) និងប្រសិនបើមានសន្តតិជនច្រើននាក់ ត្រូវសមាមាត្រនៃចំណែកមតិក។ មតិកត្រូវចាត់ទុកថាជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន នៅពេលមិនទាន់មានការបែងចែកត្រឹមត្រូវតាមច្បាប់ ឬឆន្ទៈ ឬការពិភាក្សា ដែលមានលក្ខណៈអាចទទួលយកបានទាំងអស់គ្នា។

សន្តតិកម្មត្រូវចាប់ផ្តើមដោយសារមរណភាពរបស់មតកជន។ សន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬផ្អែកតាមឆន្ទៈរបស់មតកជន។ សន្តតិកម្មផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា **សន្តតិកម្មតាមច្បាប់**។ សន្តតិកម្មផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា **សន្តតិកម្មតាមមតកសាសន៍**។

### ១.សន្តតិជន

#### ១.១.សន្តតិជនតាមច្បាប់

ច្បាប់បានកំណត់បុគ្គលដែលមានលក្ខណៈសម្បត្តិជាសន្តតិជន ដូចខាងក្រោម ៖

**សន្តតិជនលំដាប់ទី១** ៖ កូនរបស់មតកជន (កូនបង្កើតក្តី ឬកូនសុំក្តី) (CC#1156)។ មួយវិញទៀត បើកូនរបស់មតកជនបានទទួលមរណភាព នៅមុន ឬព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម ឬបាត់បង់សិទ្ធិសន្តតិកម្ម របបស្តីពីសន្តតិកម្មជំនួសនឹងត្រូវបានយកមកអនុវត្ត។

**សន្តតិជនលំដាប់ទី២** ៖ ផ្ទុយទៅវិញ ប្រសិនបើ មតកជន ពុំមានបច្ឆាញាតិផ្ទាល់នោះទេ បុព្វញាតិផ្ទាល់ ដូចជា ឪពុកម្តាយ ជីដូនជីតា ជាអាទិ៍ នឹងត្រូវទទួលបន្តមតិកនោះ(CC#1159)។

**សន្តតិជនលំដាប់ទី៣** ៖ បើមតកជនគ្មានបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់នោះទេ បងប្អូនបង្កើតរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី៣(CC#1160)។

**សន្តតិជនជានិច្ច** ៖ សន្តតិកម្មរបស់សហព័ទ្ធ ជាសិទ្ធិដែលសហព័ទ្ធត្រូវទទួលបាននូវចំណែកមត៌កពីសហព័ទ្ធម្ខាងទៀតរបស់ខ្លួន ដែលបានស្លាប់ តាមការកំណត់របស់ច្បាប់ ដោយច្បាប់បានកំណត់ថា សហព័ទ្ធ ត្រូវក្លាយជាសន្តតិជនជានិច្ច (CC#1161)។

ពាក្យ ថា "សន្តតិជនជានិច្ច" មានន័យថា អត្ថិភាពនៃសន្តតិជនផ្សេង ឬលំដាប់នៃ សន្តតិកម្មមិនត្រូវបានយកមកពិចារណាក្នុងករណីនោះឡើយ ដោយតម្រូវឲ្យសហព័ទ្ធមានលំដាប់ដូចគ្នា។ ប៉ុន្តែប្រសិនបើសន្តតិជនជានិច្ចជាអភ័ព្វបុគ្គល ឬបុគ្គលដែលត្រូវបានផ្ដាច់មត៌ក ជននោះមិនអាចទទួលសន្តតិកម្មបានឡើយ។

**សន្តតិកម្មជំនួស** ៖ ក្នុងករណីកូនរបស់មតកជនបានស្លាប់មុន ឬស្របពេលគ្នានឹងការចាប់ផ្ដើមសន្តតិកម្ម កូនរបស់ជននោះនឹងក្លាយជាសន្តតិជនជំនួស (ចៅរបស់មតកជន) (CC#1157)។ ករណីនេះ ក៏អនុវត្តផងដែរប្រសិនបើ កូនរបស់មតកជនបានបាត់បង់សិទ្ធិជាសន្តតិជន ដោយមូលហេតុជាអភ័ព្វបុគ្គល ឬត្រូវបានផ្ដាច់មត៌ក។ ក្នុងករណីកូនរបស់មតកជនជាកូនសុំ តាមរបបសុំកូនធម្មតា បានធ្វើឡើងមុនពេលកូនសុំមានកូន នៅពេលកូនសុំនោះស្លាប់មុនមតកជន កូនរបស់កូនសុំ (ចៅរបស់មតកជន) អាចទទួលបន្តមត៌កក្រោមរូបភាពជាសន្តតិកម្មជំនួស ប៉ុន្តែបើកូនសុំនោះ មានកូនមុនពេលភ្ជាប់ទំនាក់ទំនងជាកូនសុំរបស់មតកជន កូនរបស់កូនសុំនៃមតកជន មិនអាចអនុវត្តសិទ្ធិសន្តតិកម្មជំនួស(CC#940, #1015&#1027)។

ការអនុវត្តសន្តតិកម្មជំនួសនេះ គឺអាចធ្វើជាបន្តបន្ទាប់បាន សម្រាប់បច្ឆាញាតិផ្ទាល់របស់មតកជន ប្រសិនបើមានហេតុដូចមានកំណត់ខាងលើ ដូចជាករណី ប្រសិនបើ ចៅរបស់ មតកជនបានស្លាប់ ចៅទួតនឹងទទួលសន្តតិកម្មជំនួស(CC#1157-2)។

ចំណែកមត៌កនៃសន្តតិកម្មជំនួស ត្រូវទទួលបានដូចគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន និងប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ ចំណែកមត៌ករបស់បុព្វញាតិផ្ទាល់របស់ខ្លួន ត្រូវទទួលបានចំណែកស្មើៗគ្នា រវាងបច្ឆាញាតិទាំងឡាយនោះ(CC#1158)។

សន្តតិកម្មជំនួស មិនអនុវត្តចំពោះសន្តតិជនលំដាប់ទី២ (បុព្វញាតិផ្ទាល់របស់មតកជន) នោះទេ ដោយហេតុថា ទី១ បុព្វញាតិផ្ទាល់មានសិទ្ធិទទួលសន្តតិកម្ម នៅពេលមកតជនគ្មានកូន

ទី២ បើគ្មានបុព្វញាតិផ្ទាល់ គឺត្រូវបន្តទៅសន្តតិជនលំដាប់ទី៣ (បងប្អូនបង្កើត)។

សន្តតិកម្មជំនួស អាចអនុវត្តចំពោះសន្តតិជនលំដាប់ទី៣ ប៉ុន្តែទទួលស្គាល់តែមួយតំណ ប៉ុណ្ណោះ មិនអនុវត្តជាបន្តបន្ទាប់នោះទេ។ ករណីនេះ គឺមតកជន X គ្មានកូន ឪពុក-ម្តាយ គ្មានសហព័ទ្ធ ជាអាទិ៍ ប៉ុន្តែមានបងប្អូនបង្កើត ៣ (បី) នាក់ ឈ្មោះ A B & C ប៉ុន្តែ A ស្លាប់មុន X។ A មានកូន០២(ពីរ)នាក់ ឈ្មោះ $A_1$&$A_2$ ។ $A_1$&$A_2$ នឹងទទួលសន្តតិកម្មជំនួសA ត្រឹមចំណែកមតិក ដែល A មានសិទ្ធិ ប៉ុន្តែបើ A និង $A_1$&$A_2$ បានទទួលមរណភាពមុន X គឺកូនរបស់ $A_1$&$A_2$ មិនអាចទទួលសន្តតិកម្មជំនួសបាននោះទេ (ទទួលស្គាល់តែមួយតំណ) **(CC#1160-3)**។

### ១.២.អភ័ព្វបុគ្គលនៃសន្តតិកម្ម

អភ័ព្វបុគ្គល ជាជនគ្មានលក្ខណៈសម្បត្តិក្នុងការទទួលបាននូវសន្តតិកម្ម ដោយសារមានហេតុណាមួយក្នុងចំណោមហេតុ ដូចខាងក្រោម ៖

-ទទួលទោស ដោយមានចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតមតកជន ឬអ្នកមានលំដាប់សន្តតិកម្មមុន ឬស្មើ ទោះបីដោយប្រយោល ឬដោយផ្ទាល់ក្តី

-បុគ្គលដែលបានដឹងអំពីការសម្លាប់មតកជន ប៉ុន្តែមិនរាយការណ៍ ឬមិនប្តឹង លើកលែងតែបុគ្គល នោះមិនអាចវិនិច្ឆ័យល្អ ឬអាក្រក់ ឬអ្នកសម្លាប់ជាសហព័ទ្ធ ឬញាតិលោហិតខ្សែផ្ទាល់

-បុគ្គលដែលបានរារាំងមតកជន ក្នុងការលុបចោល ឬកែប្រែមតកសាសន៍ ដោយឆបោក ឬគម្រាមកំហែង

-បុគ្គលដែលបានឱ្យមតកជនធ្វើ ឬលុបចោល ឬកែប្រែមតកសាសន៍ ដោយឆបោក ឬគម្រាមកំហែង

-បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញ ឬលាក់ទុកនូវមតកសាសន៍របស់មតកជន

**១.៣.ការផ្តាច់មតិកពីសន្តតិជន** ៖ ប្រសិនបើម្ចាស់ទ្រព្យ មានឆន្ទៈមិនប្រគល់ទ្រព្យសម្បត្តិឲ្យទៅសន្តតិជន នៅពេលខ្លួនទទួលមរណភាព ម្ចាស់ទ្រព្យអាចផ្តាច់មតិកពីសន្តតិជន នោះ តាមផ្លូវតុលាការ ឬកំណត់ក្នុងមតកសាសន៍។

ប្រសិនបើម្ចាស់ទ្រព្យមានឆន្ទៈ**ផ្តាច់មតិកពីសន្តតិជនតាមផ្លូវតុលាការ** ត្រូវដាក់ពាក្យសុំដីកាសម្រេចផ្តាច់មតិក ដោយភ្ជាប់ជាមួយនឹងមូលហេតុណាមួយ ដូចខាងក្រោម ៖

-ធ្វើបាបមតកជន

-ប្រមាថមតកជន

-អាចមើលថែទាំមតកជនបាន នៅពេលមានជម្ងឺ ប៉ុន្តែមិនមើលថែទាំ

-ទទួលបានសេចក្តីសម្រេចពីតុលាការ ដាក់ពន្ធនាគារមួយជីវិត

-ប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ គួរឱ្យកត់សំគាល់ ជាអាទិ៍

ប្រសិនបើម្ចាស់ទ្រព្យមិនបានផ្តាច់មតិកពីសន្តតិជនតាមផ្លូវតុលាការ ម្ចាស់ទ្រព្យអាចសរសេរបញ្ជាក់តាមមតកសាសន៍។ **<u>ការផ្តាច់មតិកពីសន្តតិជនតាមមតកសាសន៍</u>** គឺម្ចាស់បណ្តាំបានធ្វើមតកសាសន៍ផ្តាច់មតិកពីសន្តតិជន អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មតិកពីសន្តតិជននោះ នៅពេលដែលមតកសាសន៍នោះ បង្កើតអានុភាព។ ប៉ុន្តែ មតកជន កាលនៅរស់អាចកដាក់ពាក្យសុំទៅតុលាការ ឱ្យលុបចោលនូវការផ្តាច់មតិកពីជនដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន។

**<u>ករណីសន្តតិជនជាជនបរទេស</u>** ៖ សន្តតិជនដែលពុំមានសញ្ជាតិខ្មែរ មិនអាចទទួលសន្តតិកម្មជាដីធ្លីបានឡើយ បើសន្តតិជនទាំងអស់ពុំមានសញ្ជាតិខ្មែរ ដីធ្លីដែលជាចំណែកនៃ មតិកត្រូវក្លាយជានីតិបុគ្គលមតិក ដោយសន្តតិជនទាំងអស់នោះ អាចលក់ដីធ្លីក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមតិក ក្នុងអំឡុងពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃដែលសន្តតិជនទាំងអស់យល់ព្រមជាឯកច្ឆ័ន្ទ (យល់ព្រមទាំងស្រុង ឬមានកម្រិត) ហើយថ្លៃលក់ដីធ្លីនោះ នឹងក្លាយជាមតិក នាំឱ្យនីតិបុគ្គលមតិកត្រូវរលត់។ បើមិនបានចាត់ចែងដីធ្លីនោះ នៅក្នុងអំឡុងពេល ០៣ (បី) ខែនោះទេ កម្មសិទ្ធិចំពោះដីធ្លីនោះ នឹងត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់បន្ទាប់សញ្ជាតិខ្មែរ។ បើសន្តតិជនលំដាប់បន្ទាប់គ្មានសញ្ជាតិខ្មែរនោះទេ នាំឱ្យនត្ថិភាពនៃសន្តតិជន ដែលធ្វើឱ្យដីធ្លីនោះក្លាយជាដីធ្លីគ្មានម្ចាស់ និងចុងក្រោយធ្លាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ។

គួរបញ្ជាក់ថា ប្រសិនបើអ្នកកាន់កាប់មតិកជាអភព្វបុគ្គល ឬបុគ្គលដែលផ្តាច់មតិក ច្បាប់ចាត់ទុកថា ការកាន់កាប់នោះ ជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីថ្ងៃចាប់ផ្តើមសន្តតិកម្ម។

### ១.៤.ការយល់ព្រមទទួល និងការបោះបង់សន្តតិកម្ម

សន្តតិជនត្រូវធ្វើការយល់ទ្រព្យ ឬបោះបង់សន្តតិកម្មទាំងស្រុង ឬដោយកម្រិត នៅក្នុង

អំឡុងពេល ០៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ដោយអំឡុងពេលនេះ អាចពន្យាពេលបាន តាមរយៈពាក្យសុំទៅតុលាការ ដើម្បីទុកលទ្ធភាពឲ្យសន្តតិជនធ្វើការស្រាវជ្រាវមតិក នៅមុនពេលបង្ហាញឆន្ទៈ យល់ព្រម ឬបោះបង់។ វិធាននេះជាបញ្ញត្តិសម្របសម្រួល ចំពោះសន្តតិជនដែលគ្រាន់តែទទួលសន្តតិកម្ម អាចក្ស័យធនបាន ដោយសារតែមានកាតព្វកិច្ចធ្ងន់ធ្ងរ ដោយអនុញ្ញាតឱ្យសន្តតិជននោះបោះបង់សន្តតិកម្មបាន ហើយទោះបីជាមតកជនគ្មានកាតព្វកិច្ចក៏ដោយ ក៏អាចធ្វើបានដែរ ដោយហេតុថា មិនចង់បាន ឬមិនចង់ទទួលមតិកជាមួយសហសន្តតិជនដទៃទៀតដែលខ្លួនមិនចូលចិត្ត ឬមិនសូវមានទំនាក់ទំនងល្អជាមួយគ្នា។

លើសពីនេះទៅទៀត ការកំណត់អំឡុងពេល គឺជាការពិចារណាចំពោះទំនាក់ទំនងនៃការអនុវត្តសិទ្ធិលើបំណុលចំពោះមតកជន និងសន្តតិជន ហើយការអនុញ្ញាតឱ្យពន្យាពេលតាមរយៈការដាក់ពាក្យសុំមកតុលាការ គឺជាស្ថានភាពដែលមតិកមាននៅច្រើនកន្លែង និងឱ្យតុលាការធ្វើការវិនិច្ឆ័យដោយផ្អែកលើលក្ខខណ្ឌមួយចំនួន ដូចជា គុណភាពនៃមតិក កាតព្វកិច្ចដែលទទួលដោយសន្តតិកម្ម ឬការធ្វើបញ្ជីសារពើភ័ណ្ឌ ជាអាទិ៍។

***ករណីពិសេសនៃអំឡុងពេល*** ៖ បើសន្តតិជនបានទទួលមរណភាពនៅមុនពេលធ្វើការយល់ព្រម ឬបោះបង់ នៅក្នុងអំឡុងពេលដែលបានកំណត់ដោយច្បាប់ ការគណនាអំឡុងពេលត្រូវគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះ បានដឹងថាសន្តតិកម្មចាប់ផ្តើមចំពោះខ្លួន។ មួយវិញទៀត បើសន្តតិជន ជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលកំណត់នេះ គិតចាប់ពីពេលដែលអ្នកតំណាងតាមច្បាប់កំណត់នោះ បានដឹងថា សន្តតិកម្មចំពោះអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅបានចាប់ផ្តើម មានន័យថា ប្រសិនបើសន្តតិជន ជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ យល់ព្រម ឬបោះបង់ សន្តតិកម្ម ចាំបាច់ត្រូវឱ្យអ្នកតំណាងតាមច្បាប់កំណត់ ធ្វើការសម្រេចដើម្បីសាមីខ្លួន។

លើសពីនេះទៅទៀត មតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមតិកទៅសងឱ្យបានគ្រប់ចំនួន ដោយសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ឬ ស្ថានភាពនៃទ្រព្យរបស់មតកជន ឬស្ថានភាព

ផ្សេងៗទៀត អំឡុងពេលដែលមានកំណត់នៅក្នុងច្បាប់សម្រាប់បង្ហាញឆន្ទៈយល់ព្រម ឬ បោះបង់ ត្រូវគណនាដោយគិតពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច ដោយគិតពីស្ថានភាពដែលសន្តតិជនជឿជាក់ថា មតកជនគ្មានមតិកសកម្មនោះទេ (គោលការណ៍សុចរិត និងស្មោះត្រង់)។

ម៉្យាងវិញទៀត ជាគោលការណ៍ ការយល់ព្រម ឬការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ដោយហេតុថា ការបោះបង់ ឬការយល់ព្រម មានឥទ្ធិពលយ៉ាងខ្លាំងទៅលើផលប្រយោជន៍របស់បុគ្គលពាក់ព័ន្ធ ដូចជា សន្តតិជន ឬម្ចាស់បំណុលរបស់មតកជន ជាអាទិ៍ លើកលែងតែមានអត្ថិភាពនៃវិការៈក្នុងការបង្ហាញឆន្ទៈ ដូចជា ភ័ន្តច្រឡំ ជាអាទិ៍ និងប្រសិនបើមានស្ថានភាពនេះ (វិការៈក្នុងការបង្ហាញឆន្ទៈ) អ្នកមានសិទ្ធិ ត្រូវអនុវត្តសិទ្ធិនេះក្នុងអំឡុងពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលខ្លួនបានដឹង ឬ ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីសន្តតិកម្មបានចាប់ផ្តើម តាមរយៈពាក្យសុំទៅតុលាការ។

ក្នុងករណីសន្តតិជនមិនទាន់បានបង្ហញឆន្ទៈយល់ព្រម ឬបោះបង់សន្តតិកម្ម ឬអ្នកទទួលបន្តសន្តតិកម្មមិនទាន់មានលក្ខណៈច្បាស់លាស់ ប្រសិនបើម្ចាស់បំណុលរបស់មតកជនមានបំណងធ្វើបណ្តឹង ជាបឋម ត្រូវទាមទារឲ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្តោះអាសន្ន និងអាចចាប់ផ្តើមសកម្មភាពបណ្តឹងបានចំពោះអ្នកគ្រប់គ្រងមតិកនោះ ឬម្ចាស់ទ្រព្យបានទទួលមរណភាពនៅពេលមានបណ្តឹងកំពុងត្រូវបានចាត់ការ ហើយនីតិវិធីបីណ្តឹងនោះត្រូវបានផ្អាក រហូតដល់ពេលសន្តតិជនយល់ព្រមចំពោះសន្តតិកម្ម ក៏ត្រូវឱ្យម្ចាស់បំណុលនៃមតកជន នោះទាមទារឱ្យមានអ្នកគ្រប់គ្រងមតិកបណ្តោះអាសន្ន ផងដែរ ប្រសិនចង់បន្តបណ្តឹងនោះឱ្យមានភាពឆាប់រហ័ស។

**(១) ការយល់ព្រម**

-**ការយល់ព្រមទាំងស្រុង** ៖ ក្នុងករណីដែលសន្តតិជនទទួលយល់ព្រមទាំងស្រុងនូវសន្តតិកម្ម មានន័យថា សន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ដោយតម្រូវឱ្យ បង្ហាញឆន្ទៈជាការគ្រាប់គ្រាន់ មានន័យថា មិនចាំបាច់ដាក់ពាក្យសុំទៅតុលាការ ដូចករណីយល់ព្រមដោយកម្រិត ឬបោះបង់សន្តតិកម្មនោះឡើយ។ មួយវិញទៀត

ប្រសិនបើសន្តតិជន បានធ្វើសកម្មភាពណាមួយក្នុងចំណោមសកម្មភាព ខាងក្រោមនេះ ត្រូវចាត់ទុកថា យល់ព្រមទាំងស្រុង (ការយល់ព្រមទាំងស្រុងតាមច្បាប់) ៖

+សន្តតិជនបានចាត់ចែងមត៌កនោះទាំងអស់ ឬមួយភាគ លើកលែងតែសកម្មភាពរក្សា ឬគ្រប់គ្រង

+សន្តតិជនមិនបានបង្ហាញឆន្ទៈយល់ព្រម ឬបោះបង់ នៅក្នុងអំឡុងពេល ០៣ ខែ (បី) គិតចាប់ពីពេល ដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្ដើម លើកលែងតែមានពាក្យសុំពន្យាពេលទៅតុលាការ

+ទោះបីជាសន្តតិជនបានបង្ហាញឆន្ទៈយល់ព្រម ឬបោះបង់ក៏ដោយ ប៉ុន្តែសន្តតិជនបានលាក់មត៌កទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មត៌កនោះដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន លើកែលងតែ នៅក្រោយពេលដែលជនដែល ត្រូវបានសន្មតជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ដោយហេតុថា ក្នុងករណី សន្តតិជននៃលំដាប់បន្ទាប់បានយល់ព្រម សន្តតិកម្មនេះត្រូវឱ្យទៅសន្តតិជនលំដាប់បន្ទាប់នោះ ដើម្បីមានសន្ទនាភាព និងសង្គតិភាពតាមផ្លូវច្បាប់ ហេតុនេះ ប្រសិនបើសន្តតិជនលំដាប់មុនបានធ្វើសកម្មភាពបែបនេះ សន្តតិជនលំដាប់ បន្ទាប់អាចធ្វើការទាមទារឱ្យសន្តតិជនលំដាប់មុនប្រគល់មត៌កវិញ ឬទាមទារឱ្យសងសំណងនៃការខូចខាត។

-**ការយល់ព្រមមានកម្រិត** ៖ ការយល់ព្រមដោយមានកម្រិតមានខ្លឹមសារថា ធ្វើសកម្មភាពនៃសន្តតិកម្មដែលបម្រុងសម្រាប់សងកាតព្វកិច្ចនឹងទទួលដោយសន្តត្តិកម្ម ត្រឹមកម្រិតទទួលដោយសន្តតិកម្ម មានន័យថា សន្តតិជនក្លាយទៅជាកូនបំណុល ដោយទទួលនូវសន្តតិកម្មនៃកាតព្វកិច្ចទាំងអស់របស់មតកជន ប៉ុន្តែសន្តតិជនអាចកម្រិតការទទួលខុសត្រូវបានត្រឹមកម្រិតនៃចំណែកមត៌ក លើកលែងសន្តតិជនសងកាតព្វកិច្ចដោយស្ម័គ្រចិត្ត។ មួយវិញទៀត ករណីកាតព្វកិច្ចលើសពីមត៌កសកម្ម ប្រសិនបើសន្តតិជនយល់ព្រមដោយកម្រិត ចាំបាច់ត្រូវធ្វើនីតិវិធីជម្រះបញ្ជី ដើម្បីសងម្ចាស់បំណុល ហើយបើសល់ ទើបចែង ប៉ុន្តែបើមិនសល់ មិនចាំបាច់ទទួលខុសត្រូវនោះទេ។

+*វិធី* ៖ ដើម្បីធ្វើការយល់ព្រមដោយមានកម្រិត សន្តតិជនត្រូវដាក់ពាក្យ

សុំទៅតុលាការក្នុងអំឡុងពេល ០៣ (បី) ខែ គិតចាប់ពីពេលដឹងថាសន្តតិកម្មបានចាប់ផ្តើម ចំពោះខ្លួន ប៉ុន្តែអំឡុងពេលនេះអាចពន្យាពេលបាន បើមានការអនុញ្ញាតពីតុលាការ តាមពាក្យសុំរបស់សាមីខ្លួន។ មួយវិញទៀត នៅពេលដែលដាក់ ពាក្យសុំទៅតុលាការ សន្តតិជនត្រូវដាក់បញ្ជីសារពើភ័ណ្ឌនៃមត៌ក ដោយបញ្ជាក់អំពីមត៌កសកម្ម និងមត៌កអកម្ម ដែលសន្តតិជនបានទទួល នៅពេលចាប់ផ្តើមសន្តតិកម្ម ក្នុងកម្រិតលទ្ធភាពដែលខ្លួនបានដឹង និងប្រសិនបើមិនបាន បញ្ជាក់ឱ្យច្បាស់លាស់ដោយចេតនា ត្រូវចាត់ទុកថា យល់ព្រមទាំងស្រុង។

+*អានុភាព* ៖ អានុភាពនៃការយល់ព្រមដោយកម្រិត ដែលមានខ្លឹមសារថាម្ចាស់បំណុលរបស់មតកជន មិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន នោះបានឡើយ។ ទោះបីជាដូច្នេះក៏ដោយ តាមគោលការណ៍មត៌កត្រូវធ្លាក់ទៅសន្តតិជន ប៉ុន្តែជាលក្ខណៈសារធាតុ ទ្រព្យសម្បត្តិជាមត៌កត្រូវធ្វើការជម្រះបញ្ជីផ្សេងៗពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន ហេតុនេះសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់សន្តតិជន និងមតកជន មិនអាចរលត់ដោយព្យាកុលនោះទេ។

+*ការយល់ព្រមដោយមានកម្រិត កើតឡើងមុនការយល់ព្រមតាមច្បាប់* ៖ សន្តតិជនយល់ព្រមដោយកម្រិត បើមានមូលហេតុដែលជាការទទួលខុសត្រូវទាំងស្រុងតាមផ្លូវច្បាប់ ផលប្រយោជន៍នៃការយល់ព្រមដោយកម្រិតត្រូវបានបាត់បង់។ សន្តតិជនត្រូវទទួលខុសត្រូវដូចគ្នានឹងអ្នកយល់ព្រមទាំងស្រុង។ ករណីសន្តតិជនច្រើននាក់ សន្តតិជនម្នាក់ ឬច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងនោះ មានមូលហេតុនៃការយល់ព្រមទាំងស្រុង នាំឱ្យធ្វើការជម្រះបញ្ជីមត៌ក បន្ទាប់មកបើខ្វះខាត អាចយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនដែលមានមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់មកសងបន្ថែម។ កម្រិតនៃការទទួលខុសត្រូវនេះ ទោះបីជាការយល់ព្រមដោយកម្រិតក៏ដោយ សហសន្តតិជនត្រូវទទួលបន្តនូវកាតព្វកិច្ចរបស់មតកជនទៅតាមចំណែកមត៌ក ប៉ុន្តែការទទួលខុសត្រូវមានកម្រិត ត្រឹមកម្រិតមត៌កប៉ុណ្ណោះ។ ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬច្រើននាក់ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលតាមចំណែកមត៌កនីមួយៗបាន។

**(២) ការបោះបង់**

**-វិធី** ៖ បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំទៅតុលាការនៅក្នុងអំឡុងពេល០៣ (បី) ខែ គិតចាប់ពីពេលដឹងថាសន្តតិកម្មចាប់ផ្តើមចំពោះខ្លួនលើកលែងតែមានពាក្យសុំពន្យាពេលទៅតុលាការ ហើយតុលាការអនុញ្ញាត។

**-អានុភាព** ៖ បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះ មិនមែនជាសន្តតិជន តាំងពីដំបូងមក។

## ២.ចំណែកមត៌ក

### ២.១.ចំណែកសន្តតិកម្មតាមច្បាប់

ករណីសន្តតិជន ជាកូន ចំណែកសន្តតិកម្មរបស់កូននីមួយៗគឺស្មើភាគគ្នា។

ករណីមតកជនពុំមានបច្ឆាញាតិផ្ទាល់ បុព្វញាតិផ្ទាល់ (ឪពុក-ម្តាយ ជាអាទិ៍) របស់មតកជននឹងទទួលបានចំណែកមត៌កស្មើៗគ្នា។

ករណីមតកជន ពុំមានបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់ បើបងប្អូនបង្កើតរបស់មតកជមានចំនួនច្រើននាក់នឹងទទួលបានចំណែកមត៌កស្មើៗគ្នា។ ប៉ុន្តែចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬម្តាយតែម្ខាង នឹងទទួលបានចំណែកមត៌កតែ ១/២ នៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក-ម្តាយទាំងសងខាងដូចគ្នា។

ឧទាហរណ៍ ៖ បុរស "A" បានស្លាប់ដោយបន្សល់ទុកនូវមត៌កចំនួន ១.៥០០។ បុរស "A" គ្មានប្រពន្ធ គ្មានកូន និងបុព្វញាតិនោះទេ។ បុរស "A" មានបងប្អូនបង្កើតចំនួន ០៣ (បី) នាក់ ឈ្មោះ "O" "P" និង "Q"។ ប៉ុន្តែ "Q" និង"A" គឺជាបងប្អូនរួមឪពុក និងម្តាយទីទៃ។

ករណីនេះ ចំណែកមត៌ករបស់ "O" "P" និង "Q" ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម ៖

"O" បានពីរចំណែកនៃ"Q" រីឯ "P" បានពីរចំណែគនៃ "Q" ហើយ"Q" បានមួយចំណែកហេតុនេះចំណែកមត៌ករបស់ "O" គឺ ៦០០ ចំណែកមត៌ករបស់ "P" គឺ ៦០០ និង "O" គឺ ៣០០។

ប្រសិនបើសហព័ទ្ធរបស់មតកជននិងបុគ្គលផ្សេងទៀតក្លាយជាសន្តតិជន ចំណែកមត៌កត្រូវធ្វើការបែងចែកដូចខាងក្រោម ៖

-បើសហព័ទ្ធនិងបច្ឆាញាតិផ្ទាល់ ជាសន្តតិជន នាំឱ្យទទួលចំណែកមត៌កស្មើៗគ្នា

-បើសហព័ទ្ធ និងឪពុក-ម្តាយរបស់មតកជនជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធគឺ ១/៣ រីឯឪពុក-ម្តាយ គឺ ២/៣។ ប៉ុន្តែ បើឪពុក ឬម្តាយរបស់មតកជននៅរស់តែម្នាក់ ឪពុក ឬម្តាយ ជាមួយនឹងសហព័ទ្ធនឹងទទួលបានចំណែកមត៌កស្មើៗគ្នា។

-បើសហាព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅពីឪពុក-ម្ដាយ ឬបងប្អូនបង្កើត ឬអ្នកជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមតិករបស់សហាព័ទ្ធគឺ ១/២ រីឯបុគ្គលទាំងនោះគឺ ១/២ (មាត្រា ១១៦២ នៃក្រមរដ្ឋប្បវេណី)។

**២.២ ផលប្រយោជន៍ពិសេស**

ការសម្រួលចំណែកមតិក គឺជាវិធានធ្វើឲ្យមានសមភាពជាក់ស្ដែងនៅក្នុងចំណោមសន្តតិជនដែលបានទទួលនូវផលប្រយោជន៍ពិសេស ឬប្រទានកម្ម នៅមុនពេលម្ចាស់ទ្រព្យបានស្លាប់។ ផលប្រយោជន៍ពិសេស ជាផលប្រយោជន៍ដែលបុគ្គលណាម្នាក់ ឬច្រើននាក់បានទទួលជាប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលអច្ច័យទានពីមតកជន។ អច្ច័យទានដែលត្រូវបានផ្ដល់ទៅឱ្យសន្តតិជន ក៏ត្រូវចាត់ទុកជាផលប្រយោជន៍ពិសេសផងដែរ ប៉ុន្តែពុំត្រូវរាប់បញ្ចូលក្នុងការគណនានោះទេ ព្រោះអច្ច័យទានពុំទាន់ត្រូវបានបែងចែកឱ្យទៅសន្តតិជនឡើយ នៅពេលចាប់ផ្ដើមសន្តតិកម្ម។

**មាត្រា ១១៦៣ ៖ ចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស**

១.នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាបានទទួលប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬបានទទួលអច្ច័យទានពីមតកជន តម្លៃសរុបនៃមតិកដែលមតកជនមាន នៅពេលចាប់ផ្ដើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវចាត់ទុកថាជាមតិក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីការដកតម្លៃនៃប្រទានកម្ម ឬអច្ច័យទាននោះ ចេញពីចំណែកមតិកដែលត្រូវបានគណនា តាមបញ្ញត្តិនៃផ្នែកទី១ (សន្តតិជន) និងផ្នែកទី២ (សន្តតិកម្មរបស់សហាព័ទ្ធ) គឺជាចំណែកមតិករបស់បុគ្គលនោះ។

២.បើតម្លៃនៃប្រទានកម្ម ឬអច្ច័ទាន ស្មើគ្នានឹងតម្លៃនៃចំណែកមតិក ឬលើសតម្លៃនៃចំណែកមតិកសហសន្តតិជននោះពុំអាចទទួលចំណែកមតិកនោះបានឡើយ។

នៅពេលដែលយើងស្គាល់អំពីផលប្រយោជន៍ពិសេសបានច្បាស់លាស់ហើយ យើងនឹងធ្វើការស្វែងយល់ពីអ្នកដែលទទួលបានផលប្រយោជន៍ពិសេស ចំពោះមរតករបស់ខ្លួនដោយខ្លួនបានទទួលលផលប្រយោជន៍ពិសេស និងជាសហសន្តតិជន ដែលមានចំណែក

ចំពោះមតិក ដើម្បីដឹងច្បាស់ ថាតើ ចំណែកមរតករបស់អ្នកទទួលផលប្រយោជន៍ពិសេសមានចំនួនប៉ុន្មាន នៅពេលសម្រួលចំណែករបស់ខ្លួន តាមច្បាប់។ ដោយឡែក នៅពេលមានភាគនៃវិភាគទាន ជាស្ថានភាពនៃការចំណាយទ្រព្យសម្បត្តិរបស់សហសន្តតិជនណាម្នាក់ ក្នុងចំណោមសហសន្តតិជនទាំងអស់ ដើម្បីបង្កើនទ្រព្យរបស់មតកជន ឬចំណាយសម្រាប់ជីវភាពរបស់មតកជន ឬចំណាយដើម្បីមើលថែទាំមតកជន វិធាននៃការសម្រួលចំណែកមតិកត្រូវកើតឡើង ដើម្បីឱ្យមានសមភាពជាក់ស្តែងសម្រាប់សន្តតិជនដែលបានចំណាយទ្រព្យផ្ទាល់ខ្លួន។

**កម្មវត្ថុនៃការសម្រួលចំណែកមតិក**

ជាគោលការណ៍ សន្តតិជនត្រូវទទួលបានចំណែកមតិកស្មើៗគ្នា ប៉ុន្តែប្រសិនបើ មានជនដែលទទួលផលប្រយោជន៍ពិសេស យើងមិនអាចយកចំណែកមតិកជាក់ស្តែង ទៅចែកឲ្យសន្តតិជនទាំងអស់ ដោយមិនសម្រួលចំណែកមតិកនោះទេ ព្រោះបំពានខ្លឹមសារនៃការទទួលបានចំណែកមតិកជាក់ស្តែង ដូចនេះក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីចំណែកមតិកនៃជនដែលទទួលផលប្រយោជន៍ពិសេស តាមវិធីនៃការសម្រួលចំណែក។

**β វិធីសម្រួលចំណែកមតិក**

នៅក្នុងចំណោមសហសន្តតិជនទាំងអស់ មានសន្តតិជនណាម្នាក់ ឬច្រើននាក់បានទទួលនូវប្រទានកម្ម ឬអច្ច័យទានពីមតកជន តម្លៃសរុបនៃមរតកត្រូវយកទ្រព្យរបស់មតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម បូកបញ្ចូលតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកជាមរតក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីការដកតម្លៃនៃប្រទានកម្ម ឬអច្ច័យទានចេញពីចំណែកមរតក គឺជាចំណែកមរតករបស់បុគ្គលនោះ (មាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណី)។

**<u>រូបមន្ត</u>**៖ មតិកសរុប = មតិកពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស

ចំណែកមតិកនៃអ្នកមានផលប្រយោជន៍ពិសេស = $\frac{\text{មតិកសរុប}}{\text{ចំនួនសន្តតិជន}}$ − ផលប្រយោជន៍ពិសេស

ឧទាហរណ៍ទី១៖ Â = B មតិក US$ 3.000




C ទទួលបានផលប្រយោជន៍ពិសេស US$1.000

ចម្លើយ៖ C = $\frac{3,000 + 1,000}{4}$ = 1,000 -1,000 = 0

$$B = D = E = \frac{3000 + 1000}{4} = 1.000$$

ដូច្នេះ C= 0, B= D= E =$1.000

ឧទាហរណ៍ទី២៖ Â = B មតិក $3000




C ទទួលបានផលប្រយោជន៍ពិសេស $3000

ចម្លើយ៖ $C = \frac{3000 + 3000}{4} = 1500 - 3000 = -1500$ (លើសចំណែកមតិក)

$$B = D = E = \frac{3000 + 3000}{4} = 1.500$$

ប៉ុន្តែមតិកជាក់ស្តែងមានតែ ៣.០០០ តែប៉ុណ្ណោះ មិនគ្រប់គ្រាន់សម្រាប់សន្តតិជន ០៣ នាក់ដែលត្រូវទទួលចំណែកដល់ ១៥០០ ម្នាក់ៗស្មើនឹង ៤៥០០ នោះទេ ហេតុនេះ ត្រូវសមាមាត្រ ដោយម្នាក់ៗទទួលបាន ១០០០ ហើយ C មិនទទួលបានចំណែកមតិកនោះទេ និងយោងតាមមាត្រា ១១៦៣ កថាខណ្ឌទី២ និង ១១៦៥ នៃក្រមរដ្ឋប្បវេណី C ពុំចាំបាច់បង្វិលមកវិញ។ ហេតុនេះជាលទ្ធផលចុងក្រោយ ចំណែកមតិករបស់សន្តតិជនម្នាក់ៗគឺ

B = 1000, D = 1000, E= 1000 & C = 0

តម្លៃនៃប្រទានកម្មដែលជាមូលដ្ឋាននៃការគណនា ក្នុងករណីអ្នកទទួលផលប្រយោជន៍ពិសេស បានចាត់ចែង ឬបាត់បង់ទ្រព្យដែលទទួលបានដោយប្រទានកម្ម មុនពេលចាប់ផ្តើមសន្តតិកម្ម ជាអាទិ៍ ត្រូវយកតម្លៃនៅពេលចាត់ចែង ឬបាត់បង់ទ្រព្យនោះ។ មួយវិញទៀត ប្រសិនបើកម្មវត្ថុនៃប្រទានកម្ម ជារូបិយវត្ថុអាចមានការផ្លាស់ប្តូរ ប៉ុន្តែមិនមែនជាបញ្ហាសន្តតិកម្មនោះទេ គឺជាបញ្ហានៃការបកស្រាយ ថាតើត្រូវកំណត់តម្លៃនោះនៅពេលចាប់ផ្តើមសន្តតិកម្ម ឬនៅពេលចាត់ចែង ជាអាទិ៍។ ចំណុចនេះ នៅប្រទេសជប៉ុន បកស្រាយថា កំណត់យកតម្លៃនៅពេលចាប់ផ្តើមសន្តតិកម្ម (សាលដីកាតុលាការកំពូលជប៉ុន ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៦)។

ការពិចារណារបស់តុលាការកំពូលជប៉ុនចំពោះបញ្ហានេះ គឺទី១ ទ្រព្យទាំងឡាយត្រូវសន្មតថាមិនមានការប្រែប្រួល ទី១ បើមិនសន្មត នាំឲ្យសហសន្តតិជនអាចពន្យាពេល ដើម្បីទទួលផលជាក់ស្តែងបានច្រើន ទោះបីចំណែកមតិកមិនមានការប្រែប្រួល ក៏ដោយ។

**មាត្រា ១១៦៤ ៖ តម្លៃនៃប្រទានកម្ម**

បើបដិគ្គាហក បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលបានដោយប្រទានកម្ម នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬបើទ្រព្យនោះត្រូវបានបាត់ ឬវិនាស នៅមុនពេលចាប់ផ្តើមសន្តតិកម្ម តម្លៃនៃប្រទានកម្មត្រូវគណនាតម្លៃនៅពេលចាត់ចែង ឬបាត់បង់ ឬវិនាស។ ប្រសិនបើតម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្តូរ ដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះ ត្រូវចាត់ទុកថាមានស្ថានភាពដើម នៅពេលចាប់ផ្តើមសន្តតិកម្ម។ ការប្រាក់ និងផលចំណេញដែលកើតចេញពីប្រទានកម្ម ពុំត្រូវគណនាចូលនៅក្នុងតម្លៃនោះឡើយ។

**ឧទាហរណ៍១** ៖ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឲ្យផ្ទះទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ដែលមានតម្លៃ ៣០០០ ក្រោយមក C បានលក់ផ្ទះនោះក្នុងតម្លៃ ៥០០០ បន្ទាប់ពីលក់ផ្ទះនោះបានមួយឆ្នាំ A ក៏ស្លាប់។

ផ្អែកលើអង្គហេតុនេះ តម្លៃនៃប្រទានកម្មសម្រាប់ជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ៥០០០។

**ឧទាហរណ៍២** ៖ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឲ្យផ្ទះទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ដែលមានតម្លៃ ៣.០០០ ក្រោយមកដី-ផ្ទះនោះបានបាក់ស្រុតចោលទៅទន្លេនៅឆ្នាំ ២០១៥ ហើយតាមការវាយតម្លៃដី-ផ្ទះនោះនៅឆ្នាំ ២០១៥ គឺមានតម្លៃ ២០០០។ កន្លងបាន ៣ ឆ្នាំ A ក៏ស្លាប់។

ផ្អែកលើអង្គហេតុនេះ តម្លៃនៃប្រទានកម្មសម្រាប់ជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ២០០០។

**ឧទាហរណ៍៣** ៖ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឲ្យផ្ទះទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ដែលមានតម្លៃ ៣.០០០ ក្រោយមក C បានកែសម្រួល និងធ្វើការរៀនានាលើផ្ទះនោះ ដោយចំណាយអស់ ៥.០០០ ហើយបច្ចុប្បន្នផ្ទះ-ដីនោះមានតម្លៃ ១០,០០០។ បន្ទាប់ពីកែផ្ទះនោះបានមួយឆ្នាំ A ក៏ស្លាប់។

ផ្អែកលើអង្គហេតុនេះ តម្លៃនៃប្រទានកម្មសម្រាប់ជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ៣.០០០។

**ឧទាហរណ៍៤** ៖ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឲ្យលុយចំនួន ១០,០០០ ដុល្លារអាមេរិក ទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ក្រោយមក C បាន

យកលុយនោះទៅផ្ញើនៅធនាគារតាមរូបភាព fixed deposit សម្រាប់រយៈពេល០២ ឆ្នាំ ដោយទទួលបានការប្រាក់ ៩%/ឆ្នាំ។ ០៣ ឆ្នាំក្រោយមក A ក៏ស្លាប់។

ផ្អែកលើអង្គហេតុនេះ តម្លៃនៃប្រទានកម្មសម្រាប់ជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ១០,០០០។

**៦.** ទោះបីជាផលប្រយោជន៍ពិសេសបានទទួលលើសចំណែកមត៌កក៏ដោយ ក៏មិនចាំបាច់បង្វិលសងវិញនោះទេ ហើយចំណែករបស់សន្តតិជនត្រូវសមាមាត្រ។

**មាត្រា ១១៦៥ ៖ ផលប្រយោជន៍ពិសេសលើសតម្លៃនៃចំណែកមត៌ក**

១.ទោះបីជាតម្លៃនៃប្រទានកម្ម ឬអច្ច័យទាន ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះមិនចាំបាច់បង្វិលមកវិញនូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

២.ក្នុងករណីដូចមានកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ ចំណែកមត៌ករបស់សហសន្តិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់តាមការគណនា ដោយយកមត៌កដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម ទៅបែងចែកទៅតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗ ដូចមានកំណត់ក្នុងមាត្រា ១១៦៣ ខាងលើនេះ។

**ឧទាហរណ៍** ៖ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឲ្យផ្ទះទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ដែលមានតម្លៃ ៦.០០០ និងឲ្យលុយនៅធនគារទៅ D ដែលមានចំនួន ៨.០០០។ មត៌កដែលបន្សល់ទុកគឺ ៧.០០០។ ផ្អែកតាមអង្គហេតុនេះ

មត៌កសរុប = ៧.០០០ + ៨.០០០ + ៦.០០០ = ២១.០០០

ចំណែកមត៌ករបស់ C = (២១.០០០ ៖ ៣) - ៦.០០០= ១.០០០

ចំណែកមត៌ករបស់ D = (២១.០០០ ៖ ៣) - ៨.០០០= -១.០០០

ចំណែកមត៌ករបស់ B = (២១.០០០ ៖ ៣) = ៧.០០០

ប៉ុន្តែ D មិនចាំបាច់បង្វិលសងវិញនោះទេ។ មត៌កជាក់ស្ដែងមានតែ ៧.០០០ ហេតុនេះមិនអាចឲ្យទៅ B ចំនួន ៧.០០០ និង C ចំនួន ១.០០០ នោះទេ នាំឲ្យវិធានសមាមាត្រ ត្រូវបានយកមកអនុវត្ត ដែលមានខ្លឹមសារថា ៖

C = (១.០០០ × ៧.០០០) ៖ ៨.០០០ = ៨៧៥

B = (៧.០០០ × ៧.០០០) ៖ ៨.០០០ =៦.១២៥

## ២.៣ ភាគនៃវិភាគទាន

ភាគនៃវិភាគទានគឺជាប្រភេទមួយនៃការសម្រួលចំណែកមតិក ដោយសារនៅក្នុងចំណោមសន្តតិជន មានបុគ្គលម្នាក់ ឬច្រើននាក់បានធ្វើសកម្មភាពថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ឬថែទាំព្យាបាលមតកជន ឬបានធ្វើសកម្មភាពផ្សេងៗដែលចម្រើនដល់មតកជន។ ភាគនៃវិភាគទានគឺជាការបង្រួមចំនួនមតិក ដើម្បីឲ្យមានសមភាពជាក់ស្តែងនៅក្នុងចំណោមសន្តតិជន ដោយបុគ្គលណាម្នាក់ ឬច្រើននាក់បានចំណាយសម្រាប់មតកជន មុនពេលសន្តតិកម្មចាប់ផ្តើម។

**<u>រូបមន្ត</u>៖** មតិកជាក់ស្តែង = មតិកពេលចាប់ផ្តើមសន្តតិកម្ម -ភាគនៃវិភាគទាន

ចំណែកមតិកនៃអ្នកធ្វើភាគនៃវិភាគទាន = $\frac{\text{មតិកជាក់ស្តែង}}{\text{ចំនួនសន្តតិជន}}$ + ភាគនៃវិភាគទាន

ឧទាហរណ៍ទី១៖ Â = B មតិក $៣០០០




C =$១០០០ (ភាគនៃវិភាគទាន)

មតិកជាក់ស្តែង = ៣០០០ - ១០០០ = ២០០០

ចម្លើយ៖ C= $\frac{២.០០០}{៤}$ + ១.០០០ =$១៥០០

B = D= E = $\frac{២០០០}{៤}$ = $៥០០

ដូច្នេះ C = 1500$, B=D=E= $500

ការកំណត់អំពីចំនួន ឬតម្លៃនៃភាគនៃវិភាគទានគឺសន្តតិជនពិភាក្សាគ្នាប៉ុន្តែប្រសិនបើចំនួននៃភាគនៃវិភាគទាន ភាគីអាចព្រមព្រៀងទៅតាមករណីជាក់ស្តែង ប៉ុន្តែបើការពិភាក្សាមិនទទួលបានលទ្ធផលជាវិជ្ជមាន អាចស្នើសុំមកតុលាការកំណត់ ហើយមានករណីជាដែលការបែងចែកមតិកមិនចុះសម្រុងគ្នា តម្រូវឲ្យដាក់ពាក្យសុំបែងចែកមតិកនិងទាមទារឲ្យតុលាការកំណត់តម្លៃនៃភាគនៃវិភាគទាន។

ករណីភាគនៃវិភាគទាន > ចំណែកមតិកដែលមានកំណត់ក្នុងបណ្តាំមតិក ត្រូវយកបណ្តាំមតិកជាគោល យោងតាមមាត្រា ១១៦៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

ឧទាហរណ៍




មតិក $៣០០០

C = $២០០០ (ភាគនៃវិភាគទាន)

✓ប្រសិនបើបណ្តាំបានកំណត់ថា C = ១.២០០, D = ៨០០, E=១.០០០

ដោយសារមតកសាសន៍ ឬបណ្តាំមតិកមានអានុភាពជាង ហេតុនេះត្រូវអនុវត្តតាមបណ្តាំ នាំឲ្យ C មិនទទួលបានភាគនៃវិភាគនោះទេ។

✓ប្រសិនបើបណ្តាំបានកំណត់ថា C = ៦០០, D = ៨០០, E=១.០០០

ដោយសារមតកសាសន៍ ឬបណ្តាំមតិកមានអានុភាពជាង ហេតុនេះត្រូវអនុវត្តតាមបណ្តាំ នាំឲ្យ C អាចទទួលបានភាគនៃវិភាគនោះទេតែ ៦០០ ប៉ុណ្ណោះ បន្ទាប់ពីបែងចែកឲ្យ

C = ៦០០, D = ៨០០, E=១.០០០ (៣.០០០ - ៦០០ -៨០០- ១.០០០ = ៦០០)។

◈ករណីមានភាគនៃវិភាគទាន និងផលប្រយោជន៍ពិសេស ក្នុងពេលតែមួយ

**ឧទាហរណ៍** ៖ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឲ្យផ្ទះទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ដែលមានតម្លៃ ៥.០០០ និងឲ្យលុយនៅធនគារទៅ D ដែលមានចំនួន ១.០០០។ ប៉ុន្តែ B បានចំណាយថ្លៃព្យាបាល និងធ្វើបុណ្យសពឲ្យ A ដែលមានចំនួន ៤.០០០ ហើយមតិកដែលបន្សល់ទុកគឺ ៧.០០០។ ផ្អែកតាមអង្គហេតុនេះ

មតិកសរុប = ៧.០០០ + ៥.០០០ + ១.០០០ - ៤.០០០ = ៩.០០០

ចំណែកមតិករបស់ C = (៩.០០០ ៖ ៣) - ៥.០០០= - ២.០០០

ចំណែកមតិករបស់ D = (៩.០០០ ៖ ៣) - ១.០០០= ២.០០០

ចំណែកមតិករបស់ B = (៩.០០០ ៖ ៣) + ៤.០០០ = ៧.០០០

ប៉ុន្តែ C មិនចាំបាច់បង្វិលសងវិញនោះទេ។ មតិកជាក់ស្តែងមានតែ ៧.០០០ ហេតុនេះមិនអាចឲ្យទៅ B ចំនួន ៧.០០០ និង D ចំនួន ២.០០០ នោះទេ នាំឲ្យវិធានសមាមាត្រ ត្រូវបានយកមកអនុវត្ត ដែលមានខ្លឹមសារថា ៖

D = (២.០០០ × ៧.០០០) ៖ ៩.០០០ =១.៥៥៥

B = (៧.០០០ × ៧.០០០) ៖ ៩.០០០ =៥.៤៤៥

ការតតាំងជាមួយនឹងតតិយជន មិនអាចធ្វើបានឡើយប្រសិនបើខ្វះលក្ខខណ្ឌចំពោះការសម្រួលចំណែកមតិក ពីព្រោះតតិយជនមិនដឹងអំពីសមភាពជាក់ស្តែងនៃការទទួលចំណែក

មត៌ករបស់សន្តតិជននីមួយៗនោះទេ។ លក្ខខណ្ឌតតាំងនឹងតតិយជនដែលសហសន្តតិជននីមួយៗអាចធ្វើបាន អាស្រ័យទៅលើកម្មវត្ថុនៃមត៌ក បើកម្មវត្ថុនោះជាអចលនវត្ថុ តម្រូវឲ្យធ្វើការចុះបញ្ជីអំពីការចាត់ចែង ឬចលនវត្ថុ ជាអាទិ៍ តម្រូវឲ្យកាន់កាប់ជាក់ស្តែងចំពោះវត្ថុនោះ ឬលក្ខខណ្ឌតតាំងផ្សេងៗទៀតដែលច្បាប់តម្រូវ ទៅតាមវិស័យនៃវត្ថុនីមួយៗ។

## ខ.ការរៀបចំបែងចែកមត៌ក

### ១.ការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍

✓**ការបញ្ជាក់ និងការបើកលិខិតមតកសាសន៍** ៖ មតកសាសន៍ដែលធ្វើឡើងក្រៅពីទម្រង់នៃលិខិតយថាភូត ចាំបាច់ត្រូវធ្វើការពិនិត្យ និងបញ្ជាក់។ ការពិនិត្យ និងបញ្ជាក់លិខិតមតកសាសន៍ ត្រូវធ្វើឡើងដើម្បីឱ្យជនដែលមានផលប្រយោជន៍ពាក់ព័ន្ធបានដឹងឮ និងដើម្បីកំណត់នូវខ្លឹមសារនៃមតកសាសន៍នោះ ហេតុនេះ អ្នកថែរក្សា គ្រប់គ្រងលិខិតមតកសាសន៍ត្រូវដាក់ពាក្យសុំឱ្យធ្វើការពិនិត្យបញ្ជាក់ ទៅតុលាការ នៅពេលចាប់ផ្តើមសន្តតិកម្ម និងបើបានរកឃើញលិខិតមតកសាសន៍ ក្រោយមរណភាពរបស់មតកជន ត្រូវដាក់ពាក្យសុំទៅតុលាការដោយគ្មានការយឺតយ៉ាវ។ មួយវិញទៀតចំពោះលិខិតមតកសាសន៍បិទដោយប្រថាប់ត្រា ត្រូវបើកនៅក្នុងនីតិវិធីតុលាការ ដើម្បីកុំឲ្យមានការកែប្រែ។ បើជនណាបើកលិខិតមតកសាសន៍ប្រភេទនេះ នៅក្រៅតុលាការ នឹងទទួលរងពិន័យស៊ីវិលមិនលើសពី ១.០០០.០០០ (មួយលាន) រៀល ប៉ុន្តែលិខិតមតកសាសន៍មិនត្រូវបានចាត់ទុកជាមោឃៈដោយសារមូលហេតុនេះ នោះទេ។ ការពិនិត្យបញ្ជាក់លិខិតមតកសាសន៍ គឺមានគោលបំណងបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍ ដើម្បីមានភាពច្បាស់លាស់ចំពោះឆន្ទៈពិតប្រាកដរបស់មតកជន និងទម្រង់នៃការរៀបចំមតកសាសន៍ ទៅតាមកំណត់ច្បាប់។

ករណីមតកសាសន៍មានច្រើនច្បាប់ ត្រូវពិនិត្យអំពីទម្រង់ និងខ្លឹមសារ ហើយប្រសិនបើត្រូវនឹងលក្ខខណ្ឌនៃការលុបចោលមតកសាសន៍ ត្រូវអនុវត្តតាមទម្រង់នៃការលុបចោលនោះ។

✓**ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍**៖ក្នុងករណីគ្មានអ្នកប្រតិបត្តិមតកសាសន៍ ឬបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ តាមពាក្យសុំរបស់សន្តតិជន ឬអ្នកមានប្រយោជន៍ពាក់ព័ន្ធ។ ជាគោលការណ៍ អ្នកប្រតិបត្តិមតកសាសន៍ជាអ្នកធ្វើសកម្មភាពគតិយុត្ត ក្រោយមតកសាសន៍មានអានុភាព ហេតុនេះ បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ ត្រូវបានច្បាប់កំណត់ដូចជា ជននៅក្រោម

អាណាព្យាបាលទូទៅ ជននៅក្រោមហិត្តូបត្ថម្ភ អនីតិជន និងជនធនក្ស័យ (CC#1217)។

✓**មុខងារ និងសិទ្ធិអំណាចរបស់អ្នកប្រតិបត្តិមតកសាសន៍ (ជ្រើសតាំងបន្ត)**៖ អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមតិក និងធ្វើសកម្មភាពចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍ មានន័យថា អ្នកប្រតិបត្តិមតកសាសន៍ អាចសងកាតព្វកិច្ចនៃមតិក ឬម្ចាស់បំណុលរបស់មតកជន អាចទាមទារឱ្យអ្នកប្រតិបត្តិមតកសាសន៍នោះ សងបំណុលនោះបាន ឬប្រសិនបើនៅក្នុងមតកសាសន៍មានអច្ច័យទាន អច្ច័យលាភី អាចទាមទារឱ្យអ្នកប្រតិបត្តិមតកសាសន៍ អនុវត្តអច្ច័យទាននោះ ផងដែរ។

មួយវិញទៀតអ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ដោយមានវត្តមានរបស់សន្តតិជន ហើយប្រគល់បញ្ជីនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ និងនៅពេលដែលមានវត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមតិក ឬធ្វើសកម្មភាពរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ។ អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើសកម្មភាពចំពោះមតិកដែលខ្លួនទទួលអាណត្តិ និងត្រូវមានអានុភាពចំពោះសន្តតិជន មានន័យថា បើអនុវត្ត (អ្នកតំណាងរបស់សន្តតិជន) សន្តតិជនបានបំពេញអច្ច័យទានដោយអ្នកប្រតិបត្តិមតកសាសន៍ នោះគេវាយតម្លៃថា សន្តតិជនបានបំពេញករណីយកិច្ចអច្ច័យទានដោយរាប់បញ្ចូលទាំងសកម្មភាពបណ្តឹង ហេតុនេះបើមានបណ្តឹង សន្តតិជនគឺជាតំណាង។

លើសពីនេះទៅទៀត បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចជំនួសខ្លួនឡើយ លើកលែងតែមតកជនបានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍។ បើតតិយជនអនុវត្តភារកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវទទួលខុសត្រូវចំពោះអច្ច័យលាភី និងសន្តតិជន ប្រសិនបើមានការខូចខាត (ការសងសំណងនៃការខូចខាត ជាអាទិ៍)។

✓**កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍** ៖ អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលមានកំណត់នៅក្នុងមតកសាសន៍បាន បើនៅក្នុងមតកសាសន៍ ពុំបានកំណត់កម្រៃនោះទេ តុលាការត្រូវកំណត់ចំនួនកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ ដោយពិចារណា ភាពសមរម្យនៅក្នុងការបង់កម្រៃ ស្ថានភាពនៃមតិក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និងអ្នកប្រតិបត្តិមតកសាសន៍ រាប់បញ្ចូលទាំងស្ថានភាពផ្សេងៗ។

✓**សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍** ៖ សោហ៊ុយពាក់ព័ន្ធនឹងការប្រតិបត្តិមតកសាសន៍ជាបន្ទុកនៃមត៌ក ប៉ុន្តែមិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះទេ។ សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍ មានដូចជា សោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីពិនិត្យបញ្ជាក់លិខិតមតកសាសន៍ សោហ៊ុយធ្វើបញ្ជីសារពើភ័ណ្ឌមត៌ក សោហ៊ុយគ្រប់គ្រងមត៌ក និងកម្រៃនៃអ្នកប្រតិបត្តិមតកសាសន៍ ជាអាទ៍។ មួយវិញទៀត ការកាត់សោហ៊ុយប្រតិបត្តិមតកសាសន៍នេះមិនអាចបន្ថយភាគបម្រុងបានឡើយ។

ប្រសិនបើមេធាវី ត្រូវបានជ្រើសតាំងជាអ្នកប្រតិបត្តិមតកសាសន៍ មេធាវីអាចធ្វើការស្រាវជ្រាវឯកសាររបស់មតកជន សាកសួរព័ត៌មានពីជនដែលត្រូវសន្មថាជាសន្តតិជន ចុះទៅមន្ទីរសារការី សាកសួរព័ត៌មានពីជនដែលត្រូវសន្មថាជាសន្តតិជន ជាវិធីសាស្រ្តចម្បង។ ក្នុងករណីដែលមិនច្បាស់ថាមាន ឬគ្មានមតកសាសន៍ទេ យើងអាចសាកល្បងពិភាក្សាបែងចែកមត៌ក) CC#1266)។ ក្នុងករណីមិនអាចពិភាក្សាបែងចែកបាននោះទេ នោះត្រូវបែងចែកតាមផ្លូវតុលាការ) CC#1270) និងមានលទ្ធភាពខ្ពស់ក្នុងការដឹងច្បាស់ថាមាន ឬគ្មានមតកសាសន៍ នៅក្នុងនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង) NSCC)។

**២.ការបញ្ជាក់អំពីសន្តតិជន**

នៅពេលសន្តតិកម្មចាប់ផ្ដើម ទោះបីជាសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមមតកសាសន៍ក៏ដោយ យើងត្រូវធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណសន្តតិជនឲ្យបានច្បាស់លាស់ ដោយភ្ជាប់ជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណដែលមានទំនាក់ទំនងញាតិជាមួយនឹងមតកជន ដូចជា សំបុត្រកំណើត សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ សំបុត្រមរណភាព ឬឯកសារអត្រានុកូលដ្ឋានផ្សេងទៀតដែលអាចបញ្ជាក់អំពីទំនាក់ទំនងញាតិ។

ការបែងចែកមត៌ក ដោយបូករួមទាំងជនដែលគ្មានលក្ខណៈសម្បត្តិ ក្នុងទំហំនៃសន្តតិជន ត្រូវចាត់ទុកជាមោឃៈ ដោយរាប់បញ្ចូលការបែងចែកមត៌កតាមការពិភាក្សាដោយអវត្តមានអ្នកមានលក្ខណៈសម្បត្តិមួយចំនួន។ ក្នុងករណីការទទួលស្គាល់ក្រោយមរណភាពត្រូវអនុវត្តតាមមាត្រា១២៧៤ មានន័យថា ការកំណត់សន្តតិជនផ្ដោតសំខាន់នៅមុននីតិវិធីសន្តតិកម្ម។

ទោះបីជាដឹងច្បាស់ថាមានសន្តតិជនដែលត្រូវបានកំណត់ក៏ដោយ ក៏មិនអាចក្លាយជាសន្តតិជនបានដែរ បើសិនជាសន្តតិជននោះស្លាប់ (CC#1149) ឬជាអភ័ព្វបុគ្គល (CC#1150) ឬអត្ថិភាពនៃការផ្ដាច់មត៌កពីសន្តតិជន (CC#1151)។

ប្រសិនបើសន្តតិជនជាជនបរទេស ឬគ្មានសញ្ជាតិខ្មែរ ក៏មិនអាចទទួលមត៌កជាដីធ្លី ប៉ុន្តែ

អាចចាត់ចែងក្នុងអំឡុងពេល ០៣ (បី) ខែ ដើម្បីប្តូរជាប្រាក់ បើផុតអំឡុងពេលនឹងធ្វើសន្តតិកម្មបន្ទាប់ទៅសន្តតិជនដែលមានសញ្ជាតិខ្មែរ បើគ្មានត្រូវធ្លាក់ជាសម្បត្តិរដ្ឋ**(CC#1149 &1300)**។

**៣.ការបញ្ជាក់អំពីកម្មវត្ថុនៃសន្តតិកម្ម**

កម្មវត្ថុនៃសន្តតិកម្ម គឺជាទ្រព្យផ្ទាល់របស់មតកជន ដែលអាចជា ទ្រព្យដោយឡែក និង ១/២នៃទ្រព្យរួមរបស់មតកជន បើមតកជនមានសហព័ទ្ធ ជាអាទិ៍។

ទ្រព្យរបស់មតកជន អាចជា ចលនទ្រព្យ អចលនទ្រព្យ ប្រាក់នៅក្នុងគណនីធនាគារ ឬសិទ្ធិលើបំណុលផ្សេងៗទៀត ដូចជាបំណុលដែលមតកជនមានចំពោះកូនបំណុល ជាអាទិ៍។

ដើម្បីឲ្យមានភាពច្បាស់លាស់លើអត្តសញ្ញាណនៃទ្រព្យទាំងនេះ ត្រូវមានឯកសារបញ្ជាក់អត្តសញ្ញាណទ្រព្យទាំងនេះ ដូចជា ចំពោះរថយន្ត (ប័ណ្ណសម្គាល់យានយន្ត) ដី (វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) ប្រាក់ក្នុងគណនីធនាគារ (សៀវភៅធនាគារ ឬATM Card) ប្រាក់បំណុល (កិច្ចសន្យាខ្ចីប្រាក់) ឬភាគហ៊ុន (លក្ខន្តិកៈក្រុមហ៊ុន) ឬប័ណ្ណភាគហ៊ុន។

ក្នុងករណី បែងចែកមត៌កដោយរួមបញ្ចូលទាំងទ្រព្យដែលមិនមែនជាទ្រព្យសន្តតិកម្ម នោះការពិភាក្សាបែងចែកទាំងមូលអាចក្លាយជាមោឃភាពដោយសារការភាន់ច្រឡំ ហើយបើមានទ្រព្យសន្តតិកម្មមួយផ្នែកមិនបានបញ្ចូល នោះការបែងចែកមត៌កត្រូវធ្វើសាជាថ្មីក៏មាន។ ករណីខ្លះមានវិវាទនៅតុលាការ ដោយសារតែសន្តតិជនបានអះអាងទ្រព្យសន្តតិកម្មជាទ្រព្យសម្បត្តិឯកជនតែម្នាក់ ជាអាទិ៍។ ក្នុងករណីដែលមើលឃើញច្បាស់ថាទ្រព្យអកម្មមានច្រើនជាងទ្រព្យសកម្ម យើងត្រូវធ្វើនីតិវិធីបោះបង់សន្តតិកម្មភ្លាមៗ។ ប្រសិនបើទ្រព្យអកម្មច្រើនជាងទ្រព្យសកម្ម គប្បីបង្កើតតារាងទំនងទំនងញាតិ ដើម្បីបង្ហាញឆន្ទៈយល់ព្រម ឬបោះបង់ **(CC#1260)** និងការយល់ព្រមដោយមានកម្រិត **(CC#1256)** (ជាគោលការណ៍មានអំឡុងពេល ៣ ខែគិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម **(CC#1248)**។

តម្លៃនៃកម្មវត្ថុមត៌ក ជាទូទៅត្រូវបានបំលែងជាប្រាក់តាមការសន្មត ដើម្បីងាយស្រួលក្នុងការបែងចែកមត៌ក ហេតុនេះ ជាទូទៅតុលាការកំណត់ថាតម្លៃកម្មវត្ថុមត៌ក ត្រូវសន្មត នៅពេលសន្តតិកម្មចាប់ផ្តើម។

ឧទាហរណ៍ ៖ មតកជន បានបន្សល់ទុកដី រថយន្ត លុយនៅធនាគារ គ្រឿងអលង្ការ។ បើម្ចាស់ទ្រព្យបានស្លាប់នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨ មូលដ្ឋាននៃទ្រព្យទាំងនេះ ត្រូវសន្មតនៅថ្ងៃទី ១៥ មករា ២០១៨។ យើងសន្មតថានៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨ ដីមានតម្លៃ ១០០.០០០ រថយន្តតម្លៃ ៥០.០០០ គ្រឿងអលង្ការតម្លៃ ៣០.០០០ ហេតុនេះមត៌កសរុប មានតម្លៃ ១៨០.០០០។

ចំពោះការវាយតម្លៃនៃទ្រព្យនីមួយៗ ត្រូវអនុវត្តតាមការព្រមព្រៀងរបស់សន្តតិជន ប្រសិនបើគ្មានការឯកភាពគ្នានោះទេ ភាគីអាចដាក់ពាក្យសុំទៅតុលាការ តុលាការនឹងជ្រើសតាំងអ្នកជំនាញក្នុងការវាយតម្លៃ ដោយសួរយោបល់របស់ភាគីអំពីបុគ្គលដែលតុលាការមានបំណងជ្រើសតាំង ប្រសិនបើមានយោបល់ផ្សេងគ្នា តុលាការនឹងសម្រេចដោយឆន្ទានុសិទ្ធិ។ ការពិចារណារបស់តុលាការក្នុងការជ្រើសតាំងអ្នកវាយតម្លៃ ឬអ្នកជំនាញ ជាអាទិ៍ គឺតាមរយៈការស្ទាបស្ទង់អំពីតម្លៃនៅលើទៅផ្សារ ដោយប្រមូលតម្លៃប៉ាន់ស្មាន (QUOTATION) ពីអ្នកដែលបំពេញកិច្ចការទាំងនោះ ដូចជាករណី វាយតម្លៃគ្រឿងអលង្ការ ឬរថយន្ត ជាអាទិ៍ គឺសុំតារាងប៉ាន់តម្លៃពីហាងលក់រថយន្តចំនួន ០៣ ទីតាំង ជាអាទិ៍ បន្ទាប់មកតម្លៃមធ្យមភាគ ក្នុងការកំណត់តម្លៃរួចមួយ សម្រាប់ជាមូលដ្ឋានមួយនៃតម្លៃសរុបរបស់សន្តតិកម្ម។

**៤.ការបញ្ជាក់អំពីភាគពូកិច្ច**

នៅពេលសន្តតិកម្មចាប់ផ្ដើម គប្បីស្រាវជ្រាវ ឬស្វែងយល់ពីបំណុលរបស់មតកជន ដើម្បីឲ្យមានភាពច្បាស់លាស់ ថាតើបំណុលទាំងនោះមានកម្រិតណា ច្រើនជាង ឬតិចជាងទ្រព្យដែលបន្សល់ទុក សម្រាប់ជាមូលដ្ឋានក្នុងការបង្ហាញឆន្ទៈទទួលយកមត៌កដោយកម្រិត ឬបោះបង់សន្តតិកម្ម ជាអាទិ៍។

ដើម្បីឲ្យមានភាពច្បាស់លាស់ចំពោះបំណុលរបស់មតកជន គប្បីមានឯកសារបញ្ជាក់បំណុល ដែលអាចជាកិច្ចសន្យាខ្ចីប្រាក់ ជាអាទិ៍ តាមរយៈការសាកសួរពីសន្តតិជន ឯកសារនានាដែលបន្សល់ទុក ឬបញ្ជីស្នាមផ្សេងៗ ឬតាមរយៈការប្រកាសជាសធារណៈ។ ប្រសិនបើទ្រព្យអកម្មច្រើនជាង ការបោះបង់ ឬការយល់ព្រមដោយមានកម្រិត គប្បីយកមកអនុវត្ត។ សិទ្ធិនេះត្រូវអនុវត្តក្នុងអំឡុងពេល ០៣ ខែ នៅពេលដឹងថាសន្តតិកម្មបានចាប់ផ្តើមចំពោះខ្លួន ប៉ុន្តែ រយៈពេល ៣ខែ ករណីខ្លះគឺមានលក្ខណៈមិនសមរម្យ ដោយសារថាទ្រព្យសន្តតិកម្មច្រើនប្រភេទ និងមានទីតាំងផ្សេងៗគ្នា ជាអាទិ៍។ ប្រសិនបើមានស្ថានភាពបែបនេះ ភាគីអាចស្នើសុំ ពន្យាពេល ដោយផ្អែកលើករណីដូចខាងក្រោមនេះ ៖

- ការពន្យាពេលដោយតុលាការ **(CC#1248)**
- ករណីពិសេសដែលសន្តតិជនទទួលមរណភាព **(CC#1249)**
- ករណីពិសេសក្នុងករណីអនីតិជន **(CC#1250)**
- ករណីពិសេសដែលមិនដឹងពីអត្ថិភាពនៃកាតព្វកិច្ច **(CC#1251)**

## គ.ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក

**១.លំហូរនៃការទទួលរឿងក្តីសន្តតិកម្ម**

១.១ ចំនួនសន្តតិជន ៖ សាកសួរភាគីលម្អិតអំពីបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងមត៌ករបស់មតកជន ដើម្បីដឹងឲ្យបានច្បាស់លាស់អំពីចំនួនសន្តតិជន។ ប្រសិនបើអាចកំណត់អត្តសញ្ញាណសន្តតិជនរួចហើយ ត្រូវកំណត់ប្រភេទសន្តតិជនថែមទៀត ដូចជាសន្តតិជននោះជា កូន ឬបច្ឆាញាតិផ្ទាល់ ឬជាបុគ្គលទទួលតាមសន្តតិកម្មជំនួស ឬជាសហព័ទ្ធ ឬជាឪពុក-ម្ដាយ ឬជាបងប្អូនបង្កើត ជាអាទិ៍។

១.២ ចំណែកសន្តតិកម្ម៖ នៅពេលអាចកំណត់ចំនួនសន្តតិជន និងអត្តសញ្ញាណរបស់សន្តតិជនរួចហើយ និងដឹងអំពីទំនាក់ទំនងញាតិរួចហើយ និងធ្វើការពិនិត្យបន្ត ថាតើ មានលិខិតបណ្ដាំ ឬយ៉ាងណា បើមានត្រូវអនុវត្តតាមសន្តតិកម្មតាមមតកសាសន៍ បើគ្មាន ត្រូវបែងចែកមត៌កតាមច្បាប់ ក្នុងចំណោមសន្តតិជនទាំងនោះ។

១.៣ ទំហំមត៌ក ៖ ដើម្បីមានភាពច្បាស់លាស់ត្រូវធ្វើការស្រាវជ្រាវមត៌កដែលជាកម្មវត្ថុនៃការបែងចែក គឺជាទ្រព្យសកម្មដែលមិនទាន់បានបែងចែកនៅឡើយនៅពេលបែងចែកមត៌ក នៅក្នុងចំណោមសិទ្ធិនិងករណីយកិច្ចនៃទ្រព្យសម្បត្តិរបស់មតកជននៅពេលចាប់ផ្ដើមសន្តតិកម្ម។ ក្នុងករណីដែលមានវិវាទពាក់ព័ន្ធនឹងការទទួលយកមត៌ក ត្រូវដោះស្រាយតាមនីតិវិធីរដ្ឋប្បវេណី។ ចំណុចដែលត្រូវប្រុងប្រយ័ត្នពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ អំពីទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ គឺមានតែចំណែកកម្មសិទ្ធិអវិភាគរបស់មតកជនប៉ុណ្ណោះដែលក្លាយជាមត៌ក។ ប្រសិនបើកម្មវត្ថុនៃមត៌កជាសិទ្ធិលើបំណុលជាប្រាក់ ជាទូទៅសិទ្ធិលើបំណុលនេះនឹងបែងចែកទៅតាមចំណែកនៃសន្តតិកម្មតាមច្បាប់ ប៉ុន្តែបើសិនជាមានការព្រមព្រៀងរវាងសន្តតិជន សិទ្ធិលើបំណុលនោះអាចជាកម្មវត្ថុនៃការបែងចែក ប៉ុន្តែកាតព្វកិច្ចមិនមែនជាកម្មវត្ថុនៃការបែងចែកមត៌កនោះទេ។ មួយវិញទៀត ផលពីសិទ្ធិនៃសន្តតិកម្ម ដូចជាប្រាក់សំណងការខូចខាត ជាអាទិ៍ ដែលបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬ ការបំពានកម្មវត្ថុនៃទ្រព្យសម្បត្តិសន្តតិកម្ម ប្រាក់លក់ដែលបានធ្វើលទ្ធកម្ម ជាអាទិ៍ ដោយកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ នឹងក្លាយជាកម្មវត្ថុនៃការបែងចែកមត៌ក ផងដែរ។

១.៤ការវាយតម្លៃមត៌ក៖ការវាយតម្លៃមត៌ក អាចធ្វើឡើងតាមរយៈការព្រមព្រៀងអំពីចំនួន ឬការជ្រើសតាំងអ្នកវាយតម្លៃ ឬការសន្មតនូវចំនួនជាក់លាក់ណាមួយ។ ចំពោះអចលនវត្ថុ នៅប្រទេសជប៉ុន តុលាការអាចបង្គាប់ឲ្យដាក់ឯកសារដូចជា លិខិតវាយតម្លៃទ្រព្យ លិខិតប្រកាសពន្ធសន្តតិកម្ម និងលិខិតវាយតម្លៃរបស់ក្រុមហ៊ុនអចលនវត្ថុ ដើម្បីសម្របសម្រួលយោបល់របស់ភាគី និងឈានទៅដល់ការព្រមព្រៀង។ ក្នុងករណីដែលមិនអាចព្រមព្រៀង តុលាការនឹងជ្រើសរើសអ្នកវាយតម្លៃដែលជាបុគ្គលមានចំណេះដឹង ដូចជា អ្នកជំនាញ

វាយតម្លៃអចលនវត្ថុ ជាអាទិ៍ មកធ្វើការវាយតម្លៃ។

១.៥ ការកំណត់ចំណែកមត៌កជាក់ស្តែង ៖ ចំណែកសន្តតិកម្មជាក់ស្តែង គឺជាអត្រាចំណែមត៌កចុងក្រោយដែលបានសម្រួលរួចរាល់ ដោយពិចារណាលើចំណែកសន្តតិកម្មតាមច្បាប់ជាមួយនឹងការទទួលផលប្រយោជន៍ពិសេស និងភាគនៃវិភាគទាន។ ការសម្រួលចំណែកសន្តតិកម្ម ជាវិធីមួយកំណត់ឲ្យមានសមភាពជាក់ស្តែងនៃទ្រព្យសន្តតិកម្ម។ ទ្រព្យសន្តតិកម្មនៅពេលចាប់ផ្តើមសន្តតិកម្មបូកនឹងផលប្រយោជន៍ពិសេស និងដកភាគនៃវិភាគទានចេញ ត្រូវចាត់ទុកជាជាមត៌ក។ ចំណែកសន្តតិកម្មរបស់សន្តតិជនទាំងអស់ (ចំណែកសន្តតិកម្មបណ្តោះអាសន្ន) ត្រូវគណនាឲ្យទៅតាមចំណែកសន្តតិកម្មតាមច្បាប់នៃទ្រព្យដែលត្រូវបានចាត់ទុកថាជាមត៌ក។ ចំពោះជនដែលទទួលបានផលប្រយោជន៍ពិសេស ត្រូវទទួលបានចំណែកមត៌កជាក់ស្តែងស្មើនឹងចំណែកមត៌ក ដកផលប្រយោជន៍ពិសេសដែលទទួលបានចេញ ហើយសន្តតិជនដែលទទួលបានវិភាគទាន ត្រូវទទួលបានចំណែកមត៌កជាក់ស្តែងស្មើនឹងចំណែកមត៌កបូកនឹងភាគនៃវិភាគទាន។

១.៦ ដីកាសម្រេចបែងចែកមត៌ក ៖ តុលាការត្រូវសម្រេចករណីបែងចែកមត៌កដោយពិចារណាទៅលើស្ថានភាពមួយចំនួន ដូចជា ទី១ ការបែងចែកវត្ថុដោយផ្ទាល់ ទី២ ការសម្រួលដោយបង់ជាប្រាក់ ទី៣ ការបែងចែកដោយប្តូរជាប្រាក់ ទី៤ ការបែងចែកជាវត្ថុអវិភាគដោយគិតគូរជាក់ស្តែងទៅលើស្ថានភាពរបស់សហសន្តតិជន ដូចជា អាយុ មុខរបរ សុខភាព ជីវភាព វត្ថុឬប្រភេទនៃសិទ្ធិដែលមានចំពោះមត៌ក សិទ្ធិអាទិភាពរបស់សហព័ទ្ធ សំណងនៃកាតព្វកិច្ចរបស់មតកជន ទំនៀមទម្លាប់ និងមតិយោបល់របស់សហសន្តតិជន ជាអាទិ៍។

**២.របៀបសរសេរពាក្យសុំបែងចែកមត៌ក**

២.១ អត្តសញ្ញាណភាគី អាសយដ្ឋាន និងឋានៈភាគី ៖

២.២ ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឲ្យតុលាការចេញ ៖

២.៣ អង្គហេតុដែលជាមូលហេតុនៃការទាមទារ ៖

**៣.ឯកសារភ្ជាប់**

ទី១ ឯកសារបញ្ជាក់អត្តសញ្ញាណសន្តតិជន ៖ អត្តសញ្ញាណប័ណ្ណ។

ទី២ ឯកសារបញ្ជាក់អត្តសញ្ញាណសន្តតិជន និងមតកជន ៖ សំបុត្រកំណើត សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ ជាអាទិ៍។

ទី៣ ឯកសារបញ្ជាក់អត្តសញ្ញាណទ្រព្យដែលជាកម្មវត្ថុនៃមត៌ក ៖ លិខិតបញ្ជាក់ទ្រព្យទាំងឡាយដែលជាកម្មសិទ្ធិរបស់មតកជន។

ទី៤ សំបុត្រមរណភាព ៖ លិខិតដែលបញ្ជាក់អំពីមតកជនស្លាប់។

ទី៥ ឯកសារបញ្ជាក់អំពីសិទ្ធិលើបំណុល ឬកាតព្វកិច្ច ជាអាទិ៍ ៖ កិច្ចសន្យា។

**៤.មូលដ្ឋាននៃការវិនិច្ឆ័យ**

ទី១.ការបញ្ជាក់អំពីចំណែកសន្តតិកម្មជាក់ស្តែង

ទី២.ការបញ្ជាក់អំពីខ្លឹមសារជាក់ស្តែង

ទី៣.សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ទី៤.សំណាងនៃកាតព្វកិច្ចរបស់មតកជន

ទី៥.ការបែងចែកវត្ថុជាក់ស្តែង ការបែងចែកជំនួស និងការប្តូរជាប្រាក់

ទី៦.ករណីដីជាកម្មវត្ថុមតិក

**៥.សេចក្តីសម្រេចបញ្ចប់**

សម្រេចបែងចែកមត៌ករបស់មតកជនដូចខាងក្រោម

អ្នកដាក់ពាក្យសុំ A ធ្វើលទ្ធកម្មចំណែកអវិភាគ ១ភាគ២នៃអចលនវត្ថុដូចក្នុងបញ្ជីសារពើភ័ណ្ឌ១ និង រថយន្តដូចក្នុងបញ្ជីសារពើភ័ណ្ឌ៣។

ភាគីម្ខាងទៀតនៃពាក្យសុំ B ធ្វើលទ្ធកម្មប្រាក់ក្នុងគណនីដូចក្នុងបញ្ជីសារពើភ័ណ្ឌ២។

បង្គាប់ឲ្យអ្នកដាក់ពាក្យសុំ A បង់ប្រាក់ចំនួន 35,000$ ដែលជាប្រាក់សម្រួលនៃលទ្ធកម្មមត៌កខាងលើឲ្យទៅភាគីម្ខាងទៀតនៃពាក្យសុំ B។